ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

លេខ:២២០/០៧-០៣-២០១១

សាលដីកា

លេខ១១២ ក្រ$_{IV}$ត/៣១-១២-២០១២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ:២២០ចុះថ្ងៃទី០៧-០៣-២០១១រវាង៖

-ជនជាប់ចោទឈ្មោះ[redacted]ឈើន ភេទប្រុស ជាតិខ្មែរ អាយុ៣០ឆ្នាំ កើតនៅភូមិស្មោញ ឃុំផានញើម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ មុខរបរធ្វើស្រែចំការ មានទីលំនៅ[redacted] ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ[redacted](ស)ប្រពន្ធឈ្មោះ[redacted] ទោសពីមុនគ្មាន ។(ដើមបណ្តឹងឧទ្ធរណ៍)

ឃុំខ្លួនថ្ងៃទី០៨-០៩-២០០៩

មេធាវី[redacted] សុផង់

ត្រូវចោទពីបទ:ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]រ៉ាន ភេទស្រី កំណើតឆ្នាំ១៩៦១ ជាតិខ្មែរ លំនៅបច្ចុប្បន្ន[redacted] ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ( ប្រពន្ធសពឈ្មោះ[redacted]) ។

## ៦រឿងហេតុមានដូចតទៅៈ

តាមរបាយការណ៍របស់សមត្ថកិច្ចបញ្ជាក់ថា កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ប្រមាណ៦.០០ល្ងាច ឈ្មោះ[redacted]ឈីន ,ឈ្មោះ [redacted] ផាត់ ,ឈ្មោះ[redacted] ស្គម និង ឈ្មោះ ស៊ាត បាននាំគ្នាផឹកស៊ី នៅនិងជង្រុករបស់ឈ្មោះ[redacted]ហ៊ាង (អ្នកស្នាក់នៅជាមួយនិងឈ្មោះ[redacted]ឈីន) ពេលផឹកឈ្មោះ[redacted]ហ៊ាង ក៏នៅដែរ តែមិនបានចូលរួមផឹកស៊ីទេ ។ ពេលផឹកស៊ីនោះក៏មានការឈ្លោះប្រកែកគ្នាដោយអ្នកផឹកនាំគ្នាចោទប្រកាន់ទៅលើឈ្មោះ[redacted] ហ៊ាង ថាចង់ដុតជង្រុកគេ ពេលនោះឈ្មោះ[redacted] ហ៊ាង ព្យាយាមពន្យល់បកស្រាយតែគ្មានអ្នកស្តាប់ ក៏ដើរចេញទៅពួននៅក្នុងព្រៃពោតបាត់ព្រោះខ្លាចគេ ។ពេលផឹកស៊ីរួចពួកអ្នកផឹកមានឈ្មោះ[redacted] ឈីន ឈ្មោះ[redacted]ផាត់ ,ឈ្មោះ[redacted]ស្គម និង ឈ្មោះស៊ាតបាននាំគ្នាតាមរកឈ្មោះ [redacted] ហ៊ាង ទាំងយប់ដើម្បីវាយប្រដៅ ចាប់ដាក់គុក និង បាញ់សំលាប់ចោល រហូតដល់ម៉ោងមួយរំលងអធ្រាត្រ ក៏បានទៅរកដល់ខ្ទមរបស់យាយរឿង និងបានផឹកស្រានៅតូបយាយរឿន ដោយបាននិយាយថា បើឃើញ[redacted] ហ៊ាង ឲ្យប្រាប់ផង ដល់ភ្លឺស្រាងៗ ទើបឈ្មោះ[redacted] ឈីនឈ្មោះ[redacted] ផាត់ ,ឈ្មោះ [redacted]ស្គម និង ឈ្មោះ ស៊ាតនាំគ្នាចេញទៅ ក៏ស្រាប់តែឃើញ[redacted] ហ៊ាង ចូលមកនិងនិយាយផ្តាំថា បើខ្លួនស្លាប់គ្មានអ្នកណាក្រៅពី[redacted] ឈីន ទេ រួចក៏ដើរចេញទៅទិសខាងត្បូងបាត់មួយសន្ទុះ ក៏ឃើញ[redacted] ឈីន ជិះម៉ូតូពីត្បូងមកជើង ឈ្មោះ[redacted] ហ៊ាងក៏គេចខ្លួនចូលព្រៃពោតបាត់រហូតទៅ ។លុះដល់ថ្ងៃទី០៤.០៩.២០០៩ ក៏បានរកឃើញសាកសពរបស់ឈ្មោះ [redacted] ហ៊ាង នៅក្នុងព្រៃរលួយសាច់អស់ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៣"ខ" ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១ របស់ សាលាដំបូងខេត្តបន្ទាយមានជ័យដែលបានសម្រេចៈ

I-ផ្តន្ទាទោសឈ្មោះ[redacted]ឈីន " ឃុំខ្លួន" ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួនទី ០៨-០៩-២០០៩ ពីបទៈឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិល្វា ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦-០៨-២០០៩ ។បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

II -វត្ថុតាងៈ កាំភ្លើងឆ្នៃ ( ឈើ ) ចំនួនមួយ ,ព្រួញមុខដែកដងឫស្សីចំនួនមួយ និង មួកហាមប៉ាក់ចំនួនមួយ ត្រូវរឹបអូសបំផ្លាញចោល ។

III -សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅចំពោះមុខជនជាប់ចោទ មេធាវីនិងកំបាំងមុខដើមបណ្តឹង ។ បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ថ្ងៃទី០១-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឈីន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ០៣ " ខ " ចុះថ្ងៃទី០៦-០១-២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ គ្រង់ចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី២២-០៦-២០១១ របស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted] ឈីន បានឆ្លើយបញ្ជាក់ថា កម្មករដាំសណ្តែកសៀងឲ្យខ្លួនមានឈ្មោះ [redacted]ផាត់[redacted]ស្គម និងឈ្មោះ [redacted] ហ៊ាង ហើយឈ្មោះ[redacted] ហ៊ាង ក្រោយពីស៊ីផឹករួចបានរត់មកប្រាប់ខ្លួនថា ឈ្មោះ[redacted]ផាត់រកវាយគាត់ ហើយឈ្មោះ[redacted]ផាត់នៅឈរចាំគាត់មុខជង្រុកពោតក៏ឈ្លោះគ្នា ។ ខ្លួនមិនបានទៅស៊ីផឹកនៅផ្ទះយាយរឿងទេ ហើយក៏មិនបានសម្លាប់ឈ្មោះ[redacted] ហ៊ាង ដែរ។កន្លងមកខ្លួនមិនដែលបានបណ្តេញឬទារលុយពីឈ្មោះ[redacted]ហ៊ាងទេ។សំណូមពរសុំលើកលែងចោទប្រកាន់

-តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ

ជនរងគ្រោះស្លាប់ ប៉ុន្តែកោសល្យវិច័យមិនកំណត់ថាស្លាប់ដោយសារអ្វីទេ។ការចោទប្រកាន់ក៏ដោយសារជនជាប់ចោទបញ្ចេញវាចា ដូចសាក្សីបានឆ្លើយ ហើយជនជាប់ចោទមានឧបករណ៍សំភារៈប្រើប្រាស់អាចកំណត់ថា ជនជាប់ចោទបានធ្វើសកម្មភាពអ្វីមួយនៅក្នុងកាលៈទេសៈដែលជនរងគ្រោះស្លាប់ ដោយ

គ្មានមូលហេតុ។ សមត្ថកិច្ចពុំអាចស៊ើបរកថា ជនរងគ្រោះមានទំនាស់ជាមួយអ្នកណា ហើយភស្តុតាងលើសពីវិមតិសង្ស័យសុំកំណត់ថាជាទំនាស់ផលប្រយោជន៍។សុំតម្កល់សាលក្រមសាលាដំបូងខេត្ត

មេធាវីការពារជនជាប់ចោទផ្តល់សេចក្តីសន្និដ្ឋានៈ

ក្នុងអង្គហេតុឃើញថា កើតឡើងដោយការផឹកស៊ី ឈ្មោះ [redacted] ហ៊ាង បើតាមចម្លើយសាក្សីថាគាត់ជាមនុស្សប្រមឹកពេលផឹកជួនមិនហូបបាយផង ហើយនៅក្បែរសពគាត់មានដបទឹកតែគ្មានសល់មួយដំណក់ទេ សពគ្មានស្លាកស្នាមទេ ដូចនេះ អាចស្លាប់ដោយសារខ្យល់គរ ។ សាក្សីពុំមានអ្នកណាឃើញផ្ទាល់ភ្នែកថាកូនក្តីខ្លួនសម្លាប់ឡៃ ហ៊ាងដែរ ។ សំណូមពរសុំបដិសេធសាលក្រមសាលាដំបូងចោល។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០១-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ឈើន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ០៣ " ខ " ចុះថ្ងៃទី០៦ -០១-២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទបានឆ្លើយបដិសេធថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់ ប៉ុន្តែទទួលស្គាល់ថា ជនរងគ្រោះជាកម្មកររបស់ខ្លួន ។

៣- តាមចម្លើយសាក្សីឈ្មោះ [redacted] ហ៊ុន ( ឯកសារលេខៈ០៧ ) បានបញ្ជាក់ថា ជនជាប់ចោទខឹងជនរងគ្រោះថា មានបំណងចង់ដុតជង្រុកពោតគេ ។ សាក្សីបានបញ្ជាក់ថា នៅមុនពេលជនរងគ្រោះស្លាប់ ឈ្មោះ [redacted] ឈើន បាននៅផឹកស្រានៅផ្ទះខ្លួន នៅថ្ងៃទី១៧-០៨-២០០៩ និងបានប្រាប់ខ្លួនថា និង វាយប្រដៅជនរងគ្រោះ ហើយបន្ទាប់មកបានជួបជនរងគ្រោះ និង បានលក់ស្រាឲ្យជនរងគ្រោះ ។លុះដល់ថ្ងៃទី ០៩-០៩-២០០៩ ទើបខ្លួនទទួលបានដំណឹងថាជនរងគ្រោះស្លាប់ ។

៤-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវជាប្រពន្ធជនរងគ្រោះអះអាងថា នៅថ្ងៃទី ១៦-០៨-២០០៩ ឈ្មោះ [redacted] ឈើន និង គូកនបានទៅរករឿងប្តីខ្លួន និង ចោទប្រកាន់ថា ដុតជង្រុកគាត់ ។ ប្តីខ្លួនប្រកែក ហើយគេមិនជឿ និង ដេញវ៉ៃ។ ប្តីខ្លួនខ្លាចបានរត់ចូលព្រៃ ។

៥-តាមសំអាងហេតុទី២-ទី៣-ទី៤ ខាងលើមានភស្តុតាងស៊ីសង្វាក់គួរឲ្យជឿបានថា ជនជាប់ចោទ បានប្រព្រឹត្តអំពើដូចការចោទប្រកាន់ ។

៦-សាលក្រមព្រហ្មទណ្ឌលេខៈ០៣(ខ) ចុះថ្ងៃទី០៦-០១-២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ។

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០១-០២-២០១១របស់ជនជាប់ចោទឈ្មោះ [redacted] ឈើន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ០៣(ខ)ចុះថ្ងៃទី០៦-០១-២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះ ជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ [redacted] ឈីន ប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] , [redacted] | ហត្ថលេខា: [redacted] |

---

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]